# ការដើរដោយសេចក្ដីជំនឿ

*នេះគឺជាសេចក្ដីអធិប្បាយ ដែលចែកចាយដោយលោកគ្រូគង្វាល Richard Caldwell នៅថ្ងៃពុធ ទី២៨ ខែកញ្ញា ឆ្នាំ២០១៨ នៅក្រុមជំនុំ Founders Baptist Church។*

**២កូរិនថូស ជំពូក ៥** គឺជាកន្លែងដែលយើងនឹងសិក្សាព្រះបន្ទូលរបស់ព្រះ នៅវេលាល្ងាចនេះ។ ២កូរិនថូស ជំពូកទី៥ សូមអានខ៦-៨។ យប់នេះយើងនឹងផ្តោតសំខាន់លើខ៧ ប៉ុន្តែសូមយើងចាប់ផ្តើមអានពី៦មក។ *ដូច្នេះ យើងខ្ញុំមានចិត្តជឿជាក់ជាដរាប ហើយដឹងថា ដែលយើងខ្ញុំនៅក្នុងរូបកាយនេះ នោះយើងខ្ញុំនៅឃ្លាតពីព្រះអម្ចាស់ ៧ ដ្បិតយើងខ្ញុំដើរដោយជំនឿ មិនមែនដោយមើលឃើញទេ ៨ ដូច្នេះ យើងខ្ញុំមានចិត្តជឿជាក់ ហើយក៏សុខចិត្តស៊ូចេញពីរូបកាយនេះ ទៅនៅជាមួយនឹងព្រះអម្ចាស់ជាជាង។* ខ៧ចែងថា *ដ្បិតយើងខ្ញុំដើរដោយជំនឿ មិនមែនដោយមើលឃើញទេ។*

សូមយើងបានសូមព្រះពររបស់ព្រះនៃយើងចំពោះព្រះបន្ទូលដែលត្រូវអធិប្បាយនៅវេលាយប់នេះ។ ឱព្រះវរបិតានៃយើងខ្ញុំដែលគង់នៅស្ថានសួគ៌អើយ ទូលបង្គំយើងខ្ញុំមានសេចក្ដីអំណរនៅក្នុងចិត្ត នៅខណៈពេលដែលទូលបង្គំយើងខ្ញុំបានជួបជុំគ្នានៅវេលាល្ងាចនេះ។ ជាការដ៏ណាស់ដែលបានជួបជុំជាមួយរាស្ត្ររបស់ទ្រង់។ ជាការដ៏ល្អដែលបានច្រៀងចំរៀងសរសើរទ្រង់។ ជាការដ៏ល្អដែលបានបង្ហាញនូវការអរព្រះគុណ និងបង្ហាញនូវសេចក្ដីអំណរ ជាសេចក្ដីអំណរដែលទូលបង្គំយើងបានស្គាល់ព្រះរាជបុត្រារបស់ទ្រង់។ នៅយប់នេះ ឱព្រះអម្ចាស់អើយ ទូលបង្គំយើងខ្ញុំបានមកដើម្បីស្តាប់ពីទ្រង់។ ទ្រង់បានមានបន្ទូលហើយ។ អ្វីដែលកូនទើបតែបានអាននេះគឺជាព្រះបន្ទូលរបស់ទ្រង់។ហើយទូលបង្គំសូមព្រះអង្គបានចម្រើនកំលាំងទូលបង្គំយើងខ្ញុំដើម្បីនឹងអាចទទួលបាន អាចយល់បាន ហើយបំផ្លាស់បំប្រែចិត្តទូលបង្គំយើងខ្ញុំដោយព្រះបន្ទូលនេះផងដែរ។ ព្រះអម្ចាស់អើយ បំផ្លាស់ជីវិតរបស់ទូលបង្គំយើងខ្ញុំដោយអ្វីដែលទូលបង្គំយើងខ្ញុំនឹងឮនៅយប់នេះ។ សូមបង្ហាញឥទ្ធិឫទ្ធិរបស់ទ្រង់នៅពេលបន្តិចទៀតនេះ។ សូមបង្ហាញឥទ្ធិឫទ្ធិរបស់ទ្រង់នៅកន្លែងនេះក្នុងចំណោមបងប្អូនទាំងអស់គ្នានេះ ហើយធ្វើការមួយនៅក្នុងជីវិតដែលមានតែព្រះអង្គដ៏មានព្រះជន្មគង់នៅប៉ុណ្ណោះទើបអាចពន្យល់បាន។ គ្រប់ការទាំងអស់នេះទូលបង្គំយើងទូលសូមដោយនៅក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន។

មិនមានពាក្យឥតប្រយោជន៍ណានៅក្នុងបទគម្ពីរឡើយ។ គ្រប់ទាំងព្រះបន្ទូលសុទ្ធតែត្រូវបានធ្វើតេស្តរួចជាស្រេច។ គ្រប់ទាំងព្រះបន្ទូលសុទ្ធតែត្រូវបានសំរង់ឡើង មានន័យថាគ្រប់ទាំងព្រះបន្ទូលសុទ្ធតែបរិសុទ្ធ។ គ្រប់ទាំងព្រះបន្ទូលរបស់ព្រះសុទ្ធតែមានកំណប់ទ្រព្យដ៏ហួសប្រមាណ។ តើបងប្អូនបានឈប់បន្តិចហើយជីករកកំណប់ទ្រព្យនោះនៅក្នុងព្រះបន្ទូលរបស់ព្រះដែរឬទេ? នោះគឺជាអ្វីដែលបងប្អូនកំពុងតែកាន់នៅក្នុងដៃ

នេះហើយ មែនទេ? គឺជាព្រះបន្ទូលរបស់ព្រះ? ខ្ញុំជឿជាក់ថា ប្រសិនបើបងប្អូនជីករកអ្វីមួយនៅខាងក្រោយផ្ទះរបស់បងប្អូននៅថ្ងៃស្អែកនេះ ហើយស្រាប់តែបងប្អូនជីកបានអ្វីមួយដែល George Washington បានសរសេរ នោះបងប្អូននឹងឲ្យតម្លៃវាជាមិនខាន។ បងប្អូននឹងនិយាយថា "អូ! នេះគឺឯកសារមួយដែល George Washington បានសរសេរ"។

តែអ្វីដែលបងប្អូនមាននៅក្នុងដៃយប់នេះគឺជាព្រះបន្ទូលដែលទ្រង់បណ្ដាលឲ្យសរសេរ។ នេះគឺជាព្រះបន្ទូលរបស់ព្រះអាទិករ។ ដូច្នេះចូរយើងជីកកកាយព្រះបន្ទូលនោះចុះ។

ព្រះគម្ពីរសុភាសិត 30:5 ចែងថា *"គ្រប់ទាំងព្រះបន្ទូលនៃព្រះ សុទ្ធតែបរិសុទ្ធ ទ្រង់ជាខែល ដល់អស់អ្នកដែលពឹងជ្រកក្នុងទ្រង់"*។ តើបងប្អូនមិនស្រឡាញ់ទំនាក់ទំនងបែបនោះទេឬ? គ្រប់ទាំងព្រះបន្ទូលរបស់ព្រះសុទ្ធតែពិតត្រង់ ឬព្រះបន្ទូលរបស់ទ្រង់សុទ្ធតែត្រូវបានសំរង់ឡើងឬត្រូវបានធ្វើតេស្តរួចជាស្រេច។ ទ្រង់ជាខែលដល់អស់អ្នកណាពឹងជ្រកក្នុងទ្រង់។ ព្រះវិញ្ញាណបរិសុទ្ធកំពុងតែមានបន្ទូលមកកាន់យើងរាល់គ្នាថា "អ្នករាល់គ្នាតែងតែមានសុវត្ថិភាពជានិច្ចក្នុងការដែលអ្នករាល់គ្នាជឿលើព្រះបន្ទូលរបស់ព្រះ"។ អស់អ្នកដែលពឹងជ្រកក្នុងទ្រង់ អស់អ្នកដែលជឿដល់ព្រះបន្ទូលទ្រង់ អ្នកទាំងនោះនឹងមានសុវត្ថិភាព។

គ្មានអ្វីដែលចេញមកពីព្រះឱស្ឋរបស់ព្រះដែលថាមិនសំខាន់និងម៉ឺងម៉ាត់នោះទេ ទាំងអស់សុទ្ធតែពិតត្រង់គ្រប់លក្ខណ៍ តម្រូវឲ្យស្ដាប់បង្គាប់តាម គួរទុកចិត្តទាំងស្រុងហើយសំខាន់បំផុត។ មិនមានការនិយាយជាឥតប្រយោជន៍ណាមួយនៅក្នុងបទគម្ពីរទេ។ នោះជាមូលហេតុដែលខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងនៅពេលដែលខ្ញុំមកឯព្រះបន្ទូលដ៏ស៊ីជំរៅទាំងឡាយណាដែលពុំសូវសំខាន់ក្នុងបទគម្ពីរ។ អ្នកនិពន្ធ អ្នកសរសេរបានខំធ្វើកិច្ចការនោះ ហើយបង្កើតជាករណីមួយឡើង ហើយគាត់កំពុងតែបង្ហាញពីការវែកញែកមួយ គាត់កំពុងតែនាំយើងឆ្លងកាត់នឹងរបៀបនៃការគិតមួយ ហើយបន្ទាប់មកហាក់បីដូចជាគាត់និយាយបង្គាប់មកយើងរាល់គ្នាឲ្យធ្វើតាមថា "នេះជាគំនិតមួយ នេះជាគោលការណ៍មួយសំរាប់ការរស់នៅ"។ ហើយគាត់បាននិយាយបញ្ចូលពាក្យនោះនៅកណ្ដាលការវែកញែករបស់គាត់។ វាគួរឲ្យចាប់អារម្មណ៍មែនទែនចំពោះខ្ញុំ ហើយនោះជាអ្វីដែលយើងមាននៅក្នុងខ៧។ វាជាគំនិតមួយនៅចំកណ្ដាលនៃប្រយោគពីរ។ ខ៦ "*យើងខ្ញុំមានចិត្តជឿជាក់ជាដរាប*"។ ខ៨ "*ដូច្នេះ យើងខ្ញុំមានចិត្តជឿជាក់*"។ ហើយនៅខ៧ដែលជាខកណ្ដាលនៃការវែកញែកនោះ គាត់បាននិយាយថា "*ដ្បិតយើងខ្ញុំដើរដោយជំនឿ មិនមែនដោយមើលឃើញទេ*"។

ពិតជាសំខាន់ណាស់ដែលយើងយល់ថាសំដីទាំងអស់នេះមិនមែនជាសេចក្ដីបន្ថែមដែលមិនមានសារៈសំខាន់នោះទេ ពីព្រោះសំដីទាំងនោះមិនមានន័យថា មិនសូវសំខាន់នោះទេ។ ជាញឹកញាប់ ពាក្យទាំងអស់នោះហាក់ដូចជាមិនសូវសំខាន់ពីព្រោះថា អ្នកណាៗក៏ស្គាល់ច្បាស់ពីពាក្យទាំងនោះ។ គោលការណ៍ដែលត្រូវបានដាក់បញ្ចូលនេះ ជាមាននិស្ស័យជាមូលដ្ឋានគ្រឹះ។ ហើយគោលការណ៍នេះតែងតែពាក់ព័ន្ធជានិច្ច

ជាមួយអ្វីដែលគាត់កំពុងតែពិភាក្សា។ គោលការណ៍នេះមាននិស្ស័យជាមូលដ្ឋានដ៏សំខាន់ ហើយប្រហែលជាអ្វីម្យ៉ាងដែលគាត់បាននិយាយច្រើនដងទៅកាន់បណ្ដាជនទាំងអស់នេះ។ ជាអ្វីម្យ៉ាងដែលគាត់បានបង្រៀនជាញឹកញាប់ពីមុនរួចមកហើយ ហើយគាត់គ្រាន់តែរំលឹកដល់ពួកគេអំពីការនេះប៉ុណ្ណោះ។ហាក់ដូចជាគាត់កំពុងតែនិយាយថា “យើងទាំងអស់គ្នាចងចាំពីការទាំងអស់នេះហើយ មែនទេ? អ្នកទាំងអស់គ្នាបានរៀនពីការនេះហើយ មែនទេ? ការទាំងអស់ដែលយើងកំពុងតែនិយាយ តើមិនបង្ហាញពីសេចក្ដីពិតគោលការណ៍ ដែលយើងដើរដោយជំនឿ មិនមែនដោយការមើលឃើញទេ មែនទេ?”

សំដីនេះជារបស់ប្រធានបទសំខាន់។ ប្រធានបទសំខាន់នេះវាបន្តរហូតដល់ជំពូក៤ ខ១ ហើយវាជាប្រធានបទដែលតម្លៃណាស់។

នៅក្នុងខ១នៃជំពូក៤ ចូរក្រលេកមើលថយក្រោយនៅទីនោះ។ សាវក ប៉ុល សរសេរថា *“ដូច្នេះ ដែលមានការងារនេះ នោះយើងខ្ញុំមិនណាយចិត្តឡើយ តាមខ្នាតនៃសេចក្ដីមេត្តាករុណា ដែលយើងខ្ញុំទទួលមក”*។ គាត់និយាយថា យើងមិនណាយចិត្តទេ។ ហេតុអ្វីទៅ ប៉ុល? ហេតុអ្វីបានជាយើងមិនណាយចិត្ត? ហេតុអ្វីបានជាអ្នករាល់គ្នាមិនណាយចិត្ត? គាត់បានប្រាប់យើងនៅខ១-៦ ថា ពីព្រោះគាត់ចូលរួមនឹងព័ន្ធកិច្ចនៃសេចក្ដីមេត្តាករុណា។ យើងទាំងអស់គ្នាផ្ទាល់គឺជាឧបករណ៍នៃសេចក្ដីមេត្តាករុណាដែលប្រកបដោយអំណាចនិងនាំឲ្យបានសេចក្ដីសង្គ្រោះរបស់ព្រះ ហើយឥឡូវនេះយើងកំពុងតែចូលរួមនៅក្នុងព័ន្ធកិច្ចនៃដំណឹងល្អ យើងកំពុងចូលរួមនៅក្នុងការគ្រប់គ្រងគ្រប់កិច្ចការដែលពឹងទាំងស្រុង**លើ**បំណាងព្រះហឫទ័យនៃព្រះដ៏ពោរពេញទៅដោយសេចក្ដីមេត្តាករុណាមួយអង្គ។ យើងបានទទួលសេចក្ដីសង្គ្រោះនិងព័ន្ធកិច្ចនេះដោយសារតែសេចក្ដីមេត្តាករុណារបស់ព្រះជាម្ចាស់។ ហើយដោយសេចក្ដីមេត្តាករុណានោះទៀត យើងឃើញមានលទ្ធផលនៅក្នុងព័ន្ធកិច្ចនោះ។ **ដូច្នេះយើងមិនមានការបាក់ទឹកចិត្តទេនៅពេលយើងកំពុងតែប្រកាសពីព្រះបន្ទូលរបស់ព្រះ**។ ជួនកាលនៅពេលដែលយើងមិនឃើញមនុស្សឆ្លើយតបក្នុងសេចក្ដីជំនឿចំពោះអ្វីដែលយើងបានប្រកាស យើងនឹងមិនធ្លាក់ទឹកចិត្តទេ ពីព្រោះយើងបានយល់ថា សេចក្ដីទាំងអស់នេះពឹងលើសេចក្ដីមេត្តាករុណា និងការគ្រប់គ្រងរបស់ព្រះជាម្ចាស់។

បន្ទាប់មកនៅក្នុងខ៧ ប៉ុលបាននិយាយថា នៅក្នុងជំពូក៤ដដែល "*យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជនៈដី*។ យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជនៈដី។ ហេតុអ្វីបានជាព្រះជាម្ចាស់ធ្វើបែបនេះ ប៉ុល? បងប្អូនឃើញហើយ ទ្រង់បានប្រើមនុស្សទន់ខ្សោយដើម្បីបង្ហាញថា អំណាចជារបស់ផងព្រះជាម្ចាស់ មិនមែនជារបស់យើងទេ។ នោះគឺជាអ្វីដែលគាត់ពន្យល់នៅក្នុងខ៧ដល់ខ១៥។ នៅក្នុងពួកបាវបំរើនៃព្រះបន្ទូល បងប្អូនឃើញសេចក្ដីទន់ខ្សោយ។ នៅក្នុងពួកបាវបំរើនៃព្រះបន្ទូល បងប្អូនឃើញពីសេចក្ដីស្លាប់។ ប៉ុន្តែនៅក្នុងលទ្ធផលនៃព្រះបន្ទូលរបស់ព្រះ បងប្អូនឃើញមនុស្សមកឯជីវិតវិញ។ ដូច្នេះនៅពេលដែលសេចក្ដីមេត្តាករុណានៃព្រះកំពុងធ្វើការនៅក្នុងការប្រកាសព្រះបន្ទូល ព្រះជាម្ចាស់បានសំរេចឲ្យកើតឡើងនៅក្នុងរបៀបមួយរួចស្រេចទៅហើយ គឺទ្រង់បានប្រើយើងរាល់គ្នានៅក្នុងរបៀបមួយដែលសេចក្ដីកំសោយ

របស់យើងដាក់តាំងបង្ហាញពីអំណាចព្រះចេស្តារបស់ព្រះជាម្ចាស់។ នោះជាមូលហេតុដែលយើងមិនណាយចិត្ត។

បន្ទាប់មកសូមបន្តទៅក្រោមទៀត នៅខ១៦នៃជំពូក៤។ តើគាត់បាននិយាយម្តងទៀតថាយ៉ាងដូចម្តេច? គាត់និយាយថា ដូច្នេះ *យើងខ្ញុំមិនណាយចិត្តឡើយ។*" ហេតុអ្វីទៅប៉ុល? ហេតុអ្វីបានជាលោកមិនណាយចិត្ត? គឺពីព្រោះ បងប្អូនឃើញហើយថា អ្វីដែលកំពុងធ្វើការនៅកន្លែងដែលបងប្អូនឃើញនោះមិនមែនជាចុងបញ្ចប់នោះទេ។ យើងមិនណាយចិត្តពីព្រោះយើងបានយល់អ្វីម្យ៉ាងថា មាន **និស្ស័យមួយដ៏ស្ទានមិនដល់ដែលព្រះបានតាំងឡើង**សំរាប់ជីវិតដែលយើងកំពុងរស់នៅជាអ្នកជឿនៅសម័យនេះ។ ពិតមែនហើយ នេះជាការពិតដល់ពួកសាវកផងដែរនៅពេលពួកគេបំរើដល់ព្រះបន្ទូលនៃព្រះ។ ពួកយើងជានិស្ស័យដ៏ស្ទានមិនដល់ដែលមានជីវិតមួយ ដូចជាកាលពីសម័យមុនដែរ។ ឧទាហរណ៍អំពីសេចក្តីទុក្ខលំបាក។ សូមមើលនៅខ១៦។ *ហេតុនោះយើងខ្ញុំមិនណាយ ចិត្តឡើយ ប៉ុន្តែ ទោះបើមនុស្សខាងក្រៅរបស់យើងខ្ញុំ កំពុងតែពុករលួយទៅក៏ពិតមែន តែនៅខាងក្នុងកំពុងតែកែប្រែជាថ្មីឡើងរាល់ថ្ងៃជានិច្ចវិញ ១៧ ដ្បិតសេចក្តីទុក្ខ លំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឲ្យយើងខ្ញុំមានសិរីល្អយ៉ាងធ្ងន់លើសលប់ ដ៏នៅអស់កល្បជានិច្ចវិញ* ។
ខ្ញុំចង់និយាយថា វាមើលទៅហាក់ដូចជាសេចក្តីទុក្ខលំបាកនៅពេលបច្ចុប្បន្ននេះ។ វាជាសេចក្តីទុក្ខលំបាកប៉ុន្តែយើងមិនអាចយល់ពីវាបាន។ ប៉ុន្តែវាស្រាលហើយនៅតែមួយភ្លែតប៉ុណ្ណោះ ហើយសិរីល្អលើសលប់ជាងអ្វីដែលយើងរងទុក្ខ។

បន្ទាប់មកគាត់និយាយនៅខ១៨ថា *ដោយយើងខ្ញុំមិនរាប់អាន របស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ។*
នេះជាមូលហេតុដែលយើងមិនណាយចិត្តពីព្រោះអ្វីដែលយើងមើលឃើញនោះមិនមែនជាទីបញ្ចប់នោះទេ។ នេះមិនគ្រាន់តែជាការពិតអំពីសេចក្តីទុក្ខលំបាកប៉ុណ្ណោះទេ វាក៏ពិតអំពីផ្ទះរបស់យើងនៅពេលបច្ចុប្បន្ននេះនិងកន្លែងដែលយើងរស់នៅរបូតអស់កល្បផងដែរ។

2 កូរិនថូស 5:1-5, *ពីព្រោះយើងខ្ញុំដឹងថា បើត្រសាលដែលជាទីលំនៅរបស់យើងខ្ញុំ នៅផែនដីនេះ ត្រូវបំផ្លាញវេលាណា នោះយើងខ្ញុំមានវិមាន១ ដែលមកពីព្រះ មិនមែនធ្វើនឹងដៃទេ គឺនៅលើស្ថានសួគ៌វិញ ជាវិមាននៅជាប់អស់កល្បជានិច្ច ដ្បិតនៅក្នុងត្រសាល នេះ យើងខ្ញុំតែងតែថ្ងូរ ដោយសង្វាតនឹងចង់ប្រដាប់ខ្លួន ដោយទីលំនៅរបស់យើងខ្ញុំ ជាទីលំនៅដែលមកពីស្ថានសួគ៌ណាស់ ឲ្យតែយើងខ្ញុំបានប្រដាប់ខ្លួនចុះ ដើម្បីកុំឲ្យមានឃើញយើងខ្ញុំនៅអាក្រាតឡើយ។* គាត់បន្តពិពណ៌នាអំពីសេចក្តីសន្យាដ៏មានពោរពេញដោយសិរីល្អនេះថា សេចក្តីដែលតែងតែស្លាប់ត្រូវបានលេបដោយសេចក្តីដែលមិនចេះស្លាប់វិញ។ ព្រះជា

ម្ចាស់បានប្រទានរបស់បញ្ចាំចិត្តនេះនៅក្នុង៥។ *ដ្បិតយើងខ្ញុំដែលនៅ ក្នុងត្រសាលនេះ យើងថ្ងូរមែន ដោយមានបន្ទុកយ៉ាងធ្ងន់ ពីព្រោះយើងមិនចង់ដោះសំលៀកបំពាក់នេះចេញទេ គឺចង់តែស្លៀកពាក់វិញ ដើម្បីឲ្យជីវិតបានលេបរបស់ ដែលតែងតែស្លាប់ ឲ្យបាត់ទៅនោះ  រីឯអ្នកដែលបានបង្កើតយើងខ្ញុំសំរាប់ ការនោះឯង ជាព្រះដែលទ្រង់ក៏ប្រទានព្រះវិញ្ញាណ មកបញ្ចាំចិត្តយើងខ្ញុំដែរ។*
ដូច្នេះតើគាត់បាននិយាយអ្វីនៅក្នុង៦?  *ដូច្នេះ យើងខ្ញុំមានចិត្តជឿជាក់ជានិច្ច។* តើបងប្អូនឃើញពី ទំនាក់ទំនងនេះទេ? ជំពូក៤ ១ *យើងខ្ញុំមិនណាយចិត្តឡើយ។* ជំពូក៤ ១៦ *យើងខ្ញុំមិនណាយចិត្តឡើ យ។* ជំពូក៥ ៦ *ដូច្នេះ យើងខ្ញុំមានចិត្តជឿជាក់ជានិច្ច។* នេះគ្រាន់តែជាគឺជារបៀបមួយទៀតក្នុងការ និយាយថា *យើងខ្ញុំមិនណាយចិត្ត* ប៉ុណ្ណោះ។
ជំពូក៥ ៨ បានចាប់ផ្តើមយ៉ាងដូច្នេះថា *ដូច្នេះ យើងខ្ញុំមានចិត្តជឿជាក់*។ នោះឯងជាប្រធានបទអំពីផ្នែក នេះទាំងមូល។ យើងមិនណាយចិត្តកាលដែលយើងកំពុងនៅកណ្តាលសេចក្តីទុក្ខលំបាកទាំងអស់នោះទេ។ បងប្អូនដឹងថាគំនិតបន្ថែមដែលនៅចំកណ្តាល៦និង៨មានអត្ថន័យជ្រាលជ្រៅណាស់គឺថា *ដ្បិតយើងខ្ញុំ ដើរដោយជំនឿ មិនមែនដោយមើលឃើញទេ។*
ការនោះប្រើប្រាស់ការរែកញែកនោះទាំងស្រុង មែនទេ? ការនោះប្រើប្រាស់អ្វីៗដែលយើងទើបតែបាន ឃើញនៅ១ដល់១៨នៃជំពូក៤និងក្នុងជំពូក៥រហូតដល់ខរបស់យើងនិងខទៅមុខទៀតផងដែរ។ អ្វី ដែលយើងអាចតភ្ជាប់ការទាំងអស់នេះរួមគ្នាមកគំនិត យើងបានគំនិតមួយគឺ “យើងមិនដើរដោយមើល ឃើញទេ យើងដើរដោយសេចក្តីជំនឿវិញ”។ ដូច្នេះចូរយើងគិតអំពីការនោះនៅពេលយប់នេះជាមួយគ្នា។

ខ្ញុំចង់សួរ ហើយចង់ឲ្យបងប្អូនឆ្លើយ៥សំនួរអំពីអត្ថបទរបស់យើងនៅក្នុង៧។ ទីមួយគឺ តើវាន័យថា ម៉េច? តើសាវក ប៉ុលចង់មានន័យថាម៉េច នៅពេលដែលគាត់និយាយថា *ដ្បិតយើងដើរដោយជំនឿ មិន មែនដោយការមើលឃើញទេ?* ចូរយើងចាប់ផ្តើមជាមួយអ្វីដែលនៅចំកណ្តាលនៃអត្ថបទនេះ ត្រង់ពាក្យ ថា *យើងដើរ*។ យើងដើរ ហើយគាត់ប្រាប់យើងពីរបៀបដែលយើងដើរហើយគាត់បានប្រាប់យើងពីរអ្វី ដែលមិនមែនរបៀបនៃការដើររបស់យើង។ ប៉ុន្តែទីមួយ យើងត្រូវយល់ពីពាក្យដែលគាត់ថា *យើងដើរ* មានន័យយ៉ាងដូចម្តេច? អ្នកណាដើរ ប៉ុល? ពិតមែនហើយគាត់ចង់និយាយរួមទាំងខ្លួនរបស់គាត់និងពួក សាវកឯទៃនៅក្នុងអត្ថបទនោះ ប៉ុន្តែក៏រួមទាំងអ្នកអានផងដែរ ពីព្រោះអ្វីដែលគាត់កំពុងនិយាយនៅទីនេះ សំដៅរួមទាំងអ្នកអាននិងរូបគាត់ផងដែរ។ នេះគឺជាអត្ថបទអំពីអ្នកជឿទាំងអស់។ គ្មានអ្វីក្រៅពីជីវិតនៃ សេចក្តីជំនឿនោះទេ។ យើងទាំងអស់គ្នាដែលជាអ្នកជឿ យើងដើរដោយសេចក្តីជំនឿ មិនមែនដោយការ មើលឃើញទេ។ គាត់បានសរសេរនៅខាងដើមជំពូក៤រួចមកហើយអំពីជីវិតរបស់គាត់ ព័ន្ធកិច្ចរបស់គាត់ កំលាំងជំរុញរបស់គាត់ ហើយនិងគាត់ពិតជាចង់ឲ្យពួកជំនុំក្រុងកូរិនថូសទាំងមូលដឹងថា គាត់និងពួកសាវក ឯទៀត ជាសាវកដែលពិតប្រាកដ មិនមែនជាពួកគ្រូក្លែងក្លាយទេ។ គាត់ចង់ឲ្យពួកគេដឹងថា នេះគឺជារបៀប ដែលយើងត្រូវទុកចិត្ត ហើយជារបៀបនៃជីវិតដែលយើងស្រឡាញ់ ហើយជារបៀបជីវិតដែលយើងត្រូវ យកតំរាប់តាម។ ដូច្នេះអ្វីដែលគាត់និយាយអំពីខ្លួនគាត់ គឺសំដៅរួមទាំងគ្រីស្ទានទាំងអស់ផងដែរ។

សូមឲ្យខ្ញុំឈប់ត្រឹមនេះហើយសួរបងប្អូនថា តើការនេះនិយាយសំដៅរួមទាំងបងប្អូនដែរឬទេ? នៅពេលយប់នេះ តើបងប្អូនអាចនិយាយថា *"ខ្ញុំដើរដោយសេចក្តីជំនឿ មិនមែនដោយមើលឃើញទេ"*? ខ្ញុំដើរដោយសេចក្តីជំនឿ មិនមែនដោយការមើលឃើញទេ។ ពិតមែនហើយ ការបង្ហាញថា បងប្អូនជាបានទទួលសេចក្តីសង្គ្រោះ ប៉ុន្តែយើងនិងនិយាយថែមទៀតនៅពេលបន្តិចទៀតនេះ។ នេះគឺជាអ្វីដែលបងប្អូនត្រូវជ្រើសរើសរាល់ថ្ងៃ។ ព្រះគម្ពីរហេព្រើរ 11:6 ចែងយ៉ាងដូច្នេះថា *តែបើឥតមានសេចក្តីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថា មានព្រះមែន ហើយថា ទ្រង់ប្រទានរង្វាន់ ដល់អស់អ្នកដែលស្វែងរកទ្រង់។* គឺជាទ្រង់ បងប្អូនឃើញទេ? គឺទ្រង់ ហើយទ្រង់ប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់។ ដូច្នេះពេលដែលអ្នកនិយាយ "យើងដើរ" តើ ពាក្យ"យើង"សំដៅទៅអ្នកណា? គឺយើងរាល់គ្នាហ្នឹងឯង។ ជាអ្នកជឿ។ តើមានន័យយ៉ាងដូចម្តេច នៅពេលដែលគាត់និយាយថា "យើងដើរ"? ពិតមែនហើយគាត់ចង់មានន័យថា នេះគឺជារបៀបដែលយើងរស់នៅ។ ការដើរផ្តល់រូបភាពនៃការធ្វើចលនាទៅមុខ ឈានទៅមុខ ការរស់នៅ ការជ្រើសរើស។ ដូច្នេះនៅក្នុងពេលបច្ចុប្បន្ននេះហើយកំពុងរង់ចាំអ្វីដែលមិនទាន់មកដល់ គាត់កំពុងតែនិយាយថា នេះគឺជារបៀបដែលយើងត្រូវដើរបន្តទៀត។

ខ្ញុំនឹងសរុបនូវអ្វីដែលគាត់បាននិយាយនៅក្នុងជំពូក៤និងក្នុងជំពូក៥។ ដូច្នេះមនុស្សខាងក្រៅរបស់យើងកំពុងតែខូចទៅ នេះគឺជារបៀបដែលយើងដើរបន្ត។ ត្រូវតែបន្ត ទោះជាខណៈពេលដែលកេរ្តិ៍ឈ្មោះរបស់យើងនៅលើផែនដីនេះ ហើយនិងការព្រឹត្តិរបស់យើងមិនត្រូវបានគេឲ្យតម្លៃឲ្យដូចជាព្រះបានឲ្យតម្លៃដល់យើងក៏ដោយ។ ហើយគំនិតរបស់ទ្រង់ដែលចង់ឲ្យយើងបំរើ ទោះជានៅក្នុងខណៈពេលដែលលោកិយធ្វើបាបយើងក៏ដោយ។ នេះហើយជារបៀបដែលយើងត្រូវដើរទៅមុខ។ នៅពេលមានមនុស្សមិនស្មោះត្រង់ចំពោះព្រះបន្ទូលរបស់ព្រះ នៅជំពូក៤ ខ២និង៣ យើងនៅព័ន្ធជុំវិញដោយគ្រូក្លែងក្លាយ និងរបៀបក្លែងក្លាយចំពោះព័ន្ធកិច្ច ហើយយើងប្តេជ្ញានៅក្នុងចិត្តថា ត្រូវរស់នៅដើម្បីនិយាយនូវអ្វីដែលព្រះមានបន្ទូលប៉ុណ្ណោះ នៅជំពូក៤ ខ១៣ នេះជារបៀបដែលយើងដើរទៅមុខ។នៅពេលយើងសេចក្តីទុក្ខលំបាកដែលហាក់ដូចជាមិនស្រាលនិងហាក់ដូចជាមិននៅតែមួយភ្លែត ជួនកាលយើងមានអារម្មណ៍ថា ដូចជាសេចក្តីទុក្ខលំបាកនោះចេះតែមានបន្តជារៀងរហូត នេះជារបៀបដែលយើងដើរទៅមុខ។
នៅពេលយើងពិចារណាពីសេចក្តីស្លាប់នៅលើផែនដីនិងជីវិតអស់កល្បជានិច្ច នេះហើយជារបៀបដែលយើងដើរបន្ត។ ប៉ុលកំពុងតែនិយាយពីរបៀបដែលយើងរស់នៅ។ នេះជារបៀបដែលយើងរស់នៅក្នុងជីវិតរបស់យើងជាអ្នកជឿ។ ដូច្នេះតើយើងដើរបន្តដោយរបៀបណា? "យើងដើរដោយសេចក្តីជំនឿ"។ ប្រសិនបើបងប្អូនអានផ្នែកនេះទាំងមូល ប៉ុលបង្ហាញយ៉ាងច្បាស់នូវអ្វីដែលគាត់ចង់មានន័យ នៅពេលដែលគាត់និយាយអំពីជីវិតនៃសេចក្តីជំនឿមួយ។ នោះជាជីវិតនៃការជឿដល់ព្រះ។ ជាជីវិតនៃការជឿដល់

សេចក្តីសន្យារបស់ព្រះ។ ជាជីវិតនៃការជឿដល់ព្រះបន្ទូលរបស់ព្រះ។ តើយើងជឿព្រះបន្ទូលព្រះទេ? នោះឯងជាជីវិតនៃសេចក្តីជំនឿពេញលេញមួយដែលមិនបំប្លែងព្រះបន្ទូលរបស់ព្រះ។

តើបងប្អូនបានឃើញនៅក្នុងជំពូក៤ខ២ទេ? *"យើងខ្ញុំលះចោលអស់ទាំង ការលាក់កំបាំងដែលគួរខ្មាស ឥតប្រព្រឹត្តដោយឧបាយកល ឬបំប្លែងព្រះបន្ទូលឡើយ"*។ ឃើញទេ? យើងធ្វើតែការមួយប៉ុណ្ណោះជាមួយព្រះបន្ទូល គឺប្រកាសពីព្រះបន្ទូល។ "*គឺយើងខ្ញុំផ្ទុកផ្តាក់ខ្លួន និងបញ្ញាចិត្តរបស់មនុស្សទាំងអស់ នៅចំពោះព្រះ ដោយសំដែងសេចក្តីពិតវិញ"*។ ហើយបន្តទៅខ*១៣ ហើយដែលមានចិត្តជឿដូចគ្នា ត្រូវនឹងសេចក្តីដែលចែងទុកមកថា ខ្ញុំបានជឿ បានជាខ្ញុំនិយាយ™ នោះយើងខ្ញុំក៏ជឿដែរ បានជាយើងខ្ញុំនិយាយ"*។ អ្វីដែលព្រះជាម្ចាស់មានបន្ទូល យើងជឿ។ អ្វីដែលព្រះជាម្ចាស់មានបន្ទូល យើងនិយាយ។ អ្វីដែលព្រះជាម្ចាស់មានបន្ទូល យើងការទុកចិត្ត។ បន្ទាប់មកនៅខ១៤ "*ដោយដឹងថា ព្រះអង្គ ដែលប្រោសព្រះអម្ចាស់យេស៊ូវ ឲ្យមានព្រះជន្មរស់ឡើងវិញ ទ្រង់នឹងប្រោសឲ្យយើងខ្ញុំរស់ឡើងដែរ ដោយសារព្រះយេស៊ូវ ហើយនិងនាំយើងខ្ញុំទៅនៅចំពោះទ្រង់ជាមួយនឹងអ្នករាល់គ្នាដែរ"*។ យើងដឹងថាជាការពិតពីព្រោះ បងប្អូនឃើញទេ? នេះគឺលជាអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូល។ នោះគឺជាជីវិតនៃសេចក្តីជំនឿ។ ជាជីវិតនៃការជឿដល់ព្រះបន្ទូលរបស់ព្រះ។ វាជាជីវិតនៃការបំរើដល់អ្នកដទៃដោយការប្រកាសពីព្រះយេស៊ូវ។ ខ៥ "*យើងខ្ញុំមិនប្រកាសប្រាប់ ពីខ្លួនយើងខ្ញុំទេ គឺពីព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់វិញ"*។ វាជាជីវិតនៃការស្គាល់ការប្រាកដច្បាស់ គឺជាការប្រាកដច្បាស់នៃផែនការរបស់ព្រះជាម្ចាស់ ហើយនិងជាជីវិតដែលមានសេចក្តីអំណរនៅក្នុងរបស់បញ្ចាំចិត្តរបស់ទ្រង់។ ពីមុននេះយើងបានអានខ៥ក្នុងជំពូក៥ថា *"រីឯអ្នកដែលបានបង្កើតយើងខ្ញុំសំរាប់ការនោះឯង ជាព្រះដែលទ្រង់ក៏ប្រទានព្រះវិញ្ញាណ មកបញ្ចាំចិត្តយើងខ្ញុំដែរ"*។ ដូច្នេះសាវក ប៉ុល និយាយថា "នេះជារបៀបដែលយើងត្រូវដើរក្នុងនាមជាអ្នកជឿ។ អ្នករាល់គ្នាត្រូវដើរដោយព្រះបន្ទូលរបស់ព្រះ។ អ្នករាល់គ្នាដើរដោយសេចក្តីសន្យារបស់ព្រះ។ អ្នករាល់គ្នាត្រូវដើរដោយការទុកចិត្តនៅចរិតលក្ខណៈនៃព្រះដែលទ្រង់បង្រៀនឲ្យអ្នករាល់គ្នាអំពីអង្គទ្រង់ផ្ទាល់នៅក្នុងព្រះបន្ទូលទាំងអស់នេះ"។ បងប្អូនរាល់គ្នាត្រូវទុកចិត្តទ្រង់។ នោះឯងជាជីវិតគ្រីស្ទាន។ យើងដើរដោយសេចក្តីជំនឿ។ ឬក៏បងប្អូនអាចនិយាយជាឃ្លាបដិសេធវិញដូចជាគាត់បាននិយាយនៅក្នុងខនេះក៏បានដែរថា មិនដោយការមើលឃើញទេ។ មិនមែនដោយការមើលឃើញទេ។ នេះគឺជាជំរើសដែលតែងនៅចំពោះមុខយើងជានិច្ច។ យើងអាចជឿនូវអ្វីដែលព្រះបានមានបន្ទូលនៅពេលដែលការទាំងនោះមិនទាន់មកដល់ ឬក៏យើងអាចជឿនូវអ្វីដែលយើងឃើញនៅពេលឥឡូវនេះ។ យើងអាចដាក់ជីវិតរបស់យើង យើងអាចដាក់ជីវិតរបស់យើងនិងភាពអស់កល្បរបស់យើងផ្អែកលើព្រះបន្ទូលរបស់ព្រះ នោះជាចរិតលក្ខណៈនៃព្រះដែលបានឲ្យយើងដឹងនៅក្នុងព្រះបន្ទូលទាំងនោះថា យើងអាចដាក់ជីវិតរបស់យើងផ្អែកលើព្រះនិងព្រះបន្ទូលរបស់ទ្រង់ ឬក៏យើងអាចដើរ យើងអាចធ្វើការសំរេចចិត្ត យើងអាចជ្រើសរើស យើងអាចបង្កើតផែនការរបស់យើងដោយពឹងលើគំនិតផ្ទាល់ខ្លួនរបស់យើងក៏បាន។ ការពឹងផ្អែកលើព័ត៌មានដែលយើងទទួលពីលោកិយដែលគ្មានជំនឿ។ ការពឹងផ្អែកលើស្ថានភាពដែលយើងប្រឈមមុខក្នុងជីវិតរបស់យើង។ នោះគឺ

ជាជំរើសដែលតែងតែនៅចំពោះមុខជានិច្ច។ នោះគឺជាជំរើសដែលតែងតែនៅចំពោះមុខជានិច្ច។ តើខ្ញុំនឹងជឿលើព្រះបន្ទូលរបស់ព្រះហើយធ្វើការសំរេចចិត្តដោយពឹងផ្អែកលើព្រះបន្ទូលរបស់ព្រះ រស់នៅជាជីវិតដែលពឹងលើព្រះបន្ទូលរបស់ព្រះ ឬមួយក៏ខ្ញុំរស់នៅក្នុងពន្លឺនៃអ្វីដែលខ្ញុំឃើញនៅពេលបច្ចុប្បន្ននេះ? តើខ្ញុំនឹងរស់នៅក្នុងពន្លឺនៃពេលអនាគត អានាគតដ៏យូរអង្វែងមួយដែលជាគំនិតរបស់ព្រះបន្ទូល ឬមួយក៏ខ្ញុំនឹងរស់នៅទៅតាមពន្លឺនៃពេលបច្ចុប្បន្នដែលជាការផ្តោតលើតែលោកិយនេះវិញ? ដោយការផ្តោតលើការបណ្តោះអាសន្នដែលគ្មានការពាក់ព័ន្ធនឹងភាពអស់កល្បជានិច្ចសោះវិញ? តើខ្ញុំនឹងធ្វើអ្វី?

ប្រសិនបើយើងរស់នៅដោយសេចក្តីជំនឿ នោះមានន័យថា យើងមិនរស់នៅដោយការមើលឃើញទេ។ យើងបានអានមុននេះហើយនៅខ១៨ ជំពូក៤ថា “*ដោយយើងខ្ញុំមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ*”។ ការនោះនឹងបាត់ទៅបងប្អូនអើយ វាគ្រាន់តែជាការបណ្តោះអាសន្នប៉ុណ្ណោះ។ ហេតុនោះបានជាយើងនិយាយពីសេចក្តីឈឺចាប់ទ្រង់ហៅវាថាស្រាលហើយមានរយៈពេលតែមួយភ្លែតប៉ុណ្ណោះប្រសិនបើប្រៀបធៀបនឹងភាពអស់កល្បជានិច្ច ភាពអស់កល្បដ៏មានតម្លៃដែលយើងកំពុងតែដើរតំរង់ទៅ។ *ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ*។ ព្រះគម្ពីរហេព្រើរ១១:១ ចែងថា *រីឯសេចក្តីជំនឿ នោះគឺជាចិត្តដែលដឹងជាក់ថានឹងបានដូចសង្ឃឹម ជាសំគាល់ពីការដែលមើលមិនឃើញ*។ ចិត្តរបស់ខ្ញុំដឹងប្រាកដច្បាស់ ពីអ្វីដែលព្រះបានសន្យា ប៉ុន្តែខ្ញុំមិនអាចមើលឃើញបានទេ។ ខ្ញុំជឿជាក់។ ខ្ញុំដឹងច្បាស់។ ខ្ញុំដឹងប្រាកដថាអ្វីដែលព្រះមានបន្ទូលគឺជាការពិត។ នោះឯងជាសេចក្តីជំនឿ។ ហើយខ្ញុំក៏រស់នៅតាមជំនឿនោះឯង គឺទៅតាមអ្វីដែលទ្រង់មានបន្ទូល។ ព្រះគម្ពីររ៉ូម ៨:២៤ ចែងថា *ដ្បិតយើងបានសង្គ្រោះរួច ដោយសេចក្តីសង្ឃឹម តែសេចក្តីសង្ឃឹមដែលមើលឃើញ នោះមិនឈ្មោះថាជាសេចក្តីសង្ឃឹមទេ ដ្បិតរបស់អ្វីដែលអ្នកណាមើលឃើញហើយ នោះនឹងសង្ឃឹមចង់បានធ្វើអ្វីទៀត*។ និស្ស័យនៃជីវិតរបស់យើងនៅពេលបច្ចុប្បន្ននេះ នៅក្នុងសម័យនេះ គឺជាជីវិតមួយនៃការប្រដេញតាមនូវអ្វីដែលយើងមិនទាន់ឃើញ ការជឿនូវអ្វីដែលយើងមិនទាន់ឃើញ ការសំរេចចិត្តទៅតាមអ្វីដែលយើងមិនទាន់ឃើញ។ វាជាជីវិតនៃសេចក្តីសង្ឃឹមហើយសេចក្តីសង្ឃឹមនោះគឺជាសេចក្តីសន្យារបស់ព្រះចរិតលក្ខណៈរបស់ព្រះ ព្រះបន្ទូលរបស់ព្រះ។

ដូច្នេះ នេះគឺជាអ្វីដែលប៉ុលចង់មានន័យ ពេលដែលគាត់និយាយថា យើងដើរដោយសេចក្តីជំនឿ មិនមែនដោយការមើលឃើញទេ។ យើងកំពុងតែរស់នៅរាល់ថ្ងៃ កំពុងតែធ្វើការសំរេចចិត្ត កំពុងដើរទៅមុខ មិនមែនដោយពឹងលើអ្វីដែលនៅក្នុងបច្ចុប្បន្នដែលយើងអាចមើលឃើញនេះនោះទេ ប៉ុន្តែពឹងលើអ្វីដែលព្រះបានមានបន្ទូលវិញទោះជាព្រះបន្ទូលនោះមិនទាន់បានសំរេចនៅឡើយក៏ដោយ។ នោះជារបៀបដែលយើងរស់នៅ។ សំនួរទីពីរ៖ ហេតុអ្វីបានជាការនេះពិបាក? សាវក ប៉ុលទទួលស្គាល់ថាការនេះពិបាកដោយ

ព្រោះគាត់ចំណាយពេលដ៏វែង និងការពិពណ៌នាដ៏យូរដើម្បីរៀបរាប់ពីមូលហេតុដែលយើងមិនត្រូវណាយចិត្ត។ គាត់និយាយអំពីរឿងនេះម្តងហើយម្តងទៀត មែនទេ? យើងមិនត្រូវណាយចិត្ត។ យើងមិនត្រូវណាយចិត្ត។ យើងមានការជឿជាក់ យើងមានការជឿជាក់ជាងរាប។

ហេតុអ្វីបានជាអ្នកនិយាយបែបនេះមកកាន់យើងរាល់គ្នា ប៉ុល? ប្រាកដណាស់ពីព្រោះគាត់ដឹងថា ពីគំនិតរបស់មនុស្ស នឹងមានពេលដែលមានការណាយចិត្ត។ គាត់ដឹងថាអ្នកជឿនឹងប្រឈមមុខនឹងសេចក្តីល្បួងឲ្យធ្លាក់ទៅក្នុងការណាយចិត្តជាពិតប្រាកដណាស់នៅក្នុងលោកិយនេះ។ គាត់ដឹងថា យើងនឹងច្បាំងជាមួយនឹងសមរភូមិដ៏ធំមួយ គឺការមិនជឿ មែនទេ? តើអ្វីទៅជាភាពផ្សេងគ្នារវាងសេចក្តីជំនឿនិងអ្វីដែលយើងអាចមើលឃើញ? តើនោះគឺជាអ្វី? គឺជាការមិនជឿ។ វាគឺជាអ្វីមួយដែលព្រះជាម្ចាស់បានមានបន្ទូលផ្ទុយពីអ្វីដែលខ្ញុំអាចឃើញ។ តើបងប្អូនដឹងថាសមរភូមិដ៏ធំបំផុតដែលបងប្អូនមានជារៀងរាល់ថ្ងៃនៅក្នុងជីវិតរបស់បងប្អូន គឺជាសមរភូមិនៃសេចក្តីមិនជឿទេ? បងប្អូនអាចនឹងគិតថា ប៉ុន្តែប្រសិនបើអ្នកគិតពិចារណាអំពីការនេះ អ្នកនឹងយល់អំពីការនេះមិនខាន។ នោះឯងជាសមរភូមិដ៏ធំបំផុតដែលបងប្អូនមានជារៀងរាល់ថ្ងៃ។ តើខ្ញុំអាចជឿនូវអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលទេ? តើវាពិតប្រាកដឬទេ? តើខ្ញុំអាចធ្វើការសំរេចចិត្តបានដែរឬទេ? ខ្ញុំចង់និយាយអញ្ចេះ ចូរគិតការដ៏សាមញ្ញបំផុត។ មានម្នាក់ធ្វើបាបបងប្អូន ហើយបងប្អូនចង់ធ្វើការនោះត្រឡប់ទៅវិញ។ បាទ ហេតុអ្វីបានជាបងប្អូនមិនត្រូវតបតត្រឡប់ទៅវិញ? គឺពីព្រោះតែព្រះជាម្ចាស់ទ្រង់បានមានបន្ទូល។ ឥឡូវ តើខ្ញុំអាចជឿទ្រង់អំពីការនោះបានទេ? ឬមួយក៏ខ្ញុំត្រូវសងសឹកដោយដៃរបស់ខ្ញុំវិញ។

ហេតុផលដែលការនោះអាចនឹងពិបាកដោយព្រោះតែសេចក្តីខាងលោកិយទាំងនេះ ដោយព្រោះតែសេចក្តីបណ្តោះអាសន្នទាំងនេះ ដែលវាហាក់ដូចជាផ្ទុយទៅនឹងអ្វីដែលទ្រង់បានមានបន្ទូលសន្យាអំពីអនាគតរបស់យើង ការទាំងអស់នេះជាការពិតមែន។ ខ្ញុំគិតថា ការនោះមានសារៈសំខាន់ក្នុងការដែលត្រូវប្រកាន់ខ្ជាប់។ ជំនឿគ្រីស្ទានខុសពីអ្វីម្យ៉ាងដូចជាការអនុវត្តសេចក្តីជំនឿរបស់ពួកបូពាណ៌ មែនទេ? ខុសពីទស្សនៈវិជ្ជាដែលបណ្តាលដោយអារក្សសាតាំងដែលនិយាយថា “នេះជារបៀបដែលអ្នកត្រូវរស់នៅក្នុងជីវិតរបស់អ្នក។ ចូរអ្នករស់នៅធ្វើដូចជាគ្មានអ្វីកើតឡើងនៅពេលនេះទៅបានហើយ។ អ្នកគ្រាន់តែដាក់ចិត្តគំនិតរបស់អ្នកចូលទៅក្នុងស្ថានភាពមួយដែលអ្នកកំពុងតែដោះស្រាយថា មិននៅទីនោះទេ។ វាមិនពិតទេ។ អ្នកនឹងមិនទទួលការឈឺចាប់ជាពិតប្រាកដ។ អ្នកនឹងមិនមានជំងឺទេ។ ពិភពលោកនេះមិនមែនជាអ្វីដូចដែលអ្នកបានឃើញនោះទេ។ អ្នកគ្រាន់តែរស់នៅដូចជាគ្មានអ្វីកើតឡើងទៅបានហើយ”។ នោះមិនមែនជាសេចក្តីជំនឿរបស់គ្រីស្ទានឡើយ។ ជាការពិតណាស់ បើមើលនៅជំពូក៤ ខ ១៨ ខ្ញុំគិតថា នេះសំខាន់ណាស់។ គាត់និយាយថា “*យើងខ្ញុំមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញ*” មិនពិតទេ។ តើនោះជាអ្វីដែលគាត់និយាយឬ? គាត់មិនបាននិយាយអញ្ចឹងទេ មែនទេ? គាត់និយាយថា *នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ* មានន័យថា នោះគ្រាន់តែបណ្តោះអាសន្នប៉ុណ្ណោះ។

អូ វាជាការពិតប៉ុន្តែវាគ្រាន់តែបណ្តោះអាសន្នប៉ុណ្ណោះ ហើយ"ការដែលមើលមិនឃើញ" គឺជាការដែលព្រះជាម្ចាស់បានមានបន្ទូលប្រាប់យើងនៅ"ក្នុងព្រះបន្ទូលទ្រង់ ទាំងនោះក៏ជាការពិតដែរ។ ភាពផ្សេងគ្នាគឺថា ការដែលមើលមិនឃើញនោះ "ស្ថិតស្ថេរនៅអស់កល្បជានិច្ចវិញ"។ មួយមានរយៈពេលបណ្តោះអាសន្ន រីឯមួយទៀតស្ថិតស្ថេរនៅអស់កល្ប។

ដូច្នេះព្រះរាជសារនៃបទគម្ពីរគឺយ៉ាងនេះ៖ យើងកំពុងរស់នៅក្នុងលោកិយមួយដែលមានផ្ទុកទៅដោយគ្រប់ទាំងការសោកសង្រេងនៃការធ្លាក់ក្នុងអំពើបាប។ ខ្ញុំចង់និយាយថា វាបង្ហាញដល់យើងជារៀងរាល់ថ្ងៃថា ការធ្លាក់ក្នុងអំពើបាបគឺជាការពិត។ នៅជុំវិញយើងមានដូចជា៖ ការឈឺចាប់ ការបាត់បង់ ការសោកសង្រេង ជំងឺ ឃាតកម្ម អាត្មានិយម ការកុហក់។ ការទាំងអស់នេះ។ ការមិនស្មោះត្រង់ដែលជារបស់ជីវិតនៅក្នុងលោកិយដែលធ្លាក់ក្នុងអំពើបាបមួយ។ វាជាការពិតប្រាកដណាស់។ តើការទាំងអស់នេះកើតមកដោយរបៀបណា? នៅពេលដែលមនុស្សបានជឿដល់សេចក្តីសន្យាដ៏កុហក់របស់អារក្សសាតាំងជាជាងការពឹងដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ បទគម្ពីរប្រាប់យើងថា ការពិតនៃសេចក្តីសោកសង្រេងទាំងអស់នេះនឹងកើតមានឡើងសំរាប់ពេលមួយ ប៉ុន្តែយើងឈប់ជឿការកុហក់បោកបញ្ឆោតរបស់អារក្សទៀត ហើយយើងជឿដល់សេចក្តីសន្យារបស់ព្រះជាម្ចាស់នៅក្នុងព្រះគ្រីស្ទវិញ ហើយយើងដាក់សេចក្តីជំនឿនៅក្នុងព្រះរាជបុត្រារបស់ព្រះ ហើយបន្ទាប់មកយើងដើរតាមព្រះដ៏មានព្រះជន្មរស់នៅក្នុងព្រះគ្រីស្ទ។ អនាគត់របស់យើង អនាគត់ដ៏អស់កល្បរបស់យើងនឹងក្លាយជាអ្វីដូចជាដែលព្រះបានមានបន្ទូលប្រាប់យើង។ នោះជារបៀបដែលបងប្អូនរស់នៅនាពេលបច្ចុប្បន្ននេះ។ បងប្អូនរស់នៅក្នុងពេលបច្ចុប្បន្ននេះមិនមែនសំរាប់អ្វីដែលបងប្អូនអាចឃើញនាពេលបច្ចុប្បន្ននេះនោះទេ។ បងប្អូនរស់នៅក្នុងពេលបច្ចុប្បន្ននេះក្នុងពន្លឺនៃអ្វីដែលព្រះបានសន្យាចំពោះបងប្អូនអំពីពេលបច្ចុប្បន្ននេះនិងអំពីពេលអនាគត់អស់កល្បវិញ។

ប៉ុន្តែវាពិបាកពីព្រោះការទាំងអស់នេះជាការដែលពិតប្រាកដ។ យើងមិនបដិសេធនឹងការពិតទាំងអស់នោះនោះទេ។ យើងប្រឈមមុខនឹងការពិតទាំងអស់នេះ។ យើងប្រឈមមុខនឹងការពិតជាមួយនឹងសេចក្តីសន្យារបស់ព្រះជាម្ចាស់។ នៅពេលមនុស្សមិនឆ្លើយតមដោយសេចក្តីជំនឿចំពោះព្រះបន្ទូលដែលយើងប្រកាស នោះគឺជាអ្វីដែលគាត់កំពុងដោះស្រាយជាមួយនឹងផ្នែកដំបូងនៃជំពូក៤។ នោះគឺជាការពិតប្រាកដមែន ហើយនោះជាការដែលពិបាកពីព្រោះវាមិនមែនជាទីបញ្ចប់នៅឡើយទេ។ វាមិនមែនជាពាក្យចុងក្រោយទេ។ នៅពេលគេបៀតបៀនយើង មួលបង្កាច់ពីយើងដោយព្រោះសេចក្តីជំនឿដែលជឿដល់ព្រះគ្រីស្ទរបស់យើង។ នោះគឺជាការពិតប្រាកដមែនហើយពិបាក វាមិនមែនជាចុងបញ្ចប់ទេ។ នៅពេលដែលរូបកាយនេះកំពុងតែខូចទៅ ហើយយើងមានអារម្មណ៍ដឹងពីសេចក្តីស្លាប់នៅក្នុងលោកិយនេះ។ នោះជាការពិតប្រាកដ ហើយពិបាក ប៉ុន្តែវាមិនមែនជាចុងបញ្ចប់ទេ។ អ្វីក៏ដោយដែលច្បាំងជាមួយនឹងអ្នកនៅថ្ងៃនេះ អ្វីក៏ដោយដែលកំពុងធ្វើឲ្យពិបាកដល់ការទុកចិត្តរបស់បងប្អូនដល់ព្រះអម្ចាស់ អ្វីក៏ដោយដែលពិបាក ហើយមានការឈឺចាប់នៅក្នុងជីវិតរបស់បងប្អូន ខ្ញុំមិនអាចប្រាប់បងប្អូនថា វាមិនពិតនោះទេ ហើយខ្ញុំក៏

មិនអាចប្រាប់បងប្អូនថាវាមិនពិបាកនោះដែរ។ ខ្ញុំប្រាប់បងប្អូនថា ចូរជឿថាព្រះជាម្ចាស់គង់នៅកន្លែងដែលមានសេចក្ដីលំបាកទាំងនោះ។ ចូរទុកចិត្តដល់ទ្រង់។ ចូរជឿដល់ទ្រង់។ ចូរស្ដាប់បង្គាប់ទ្រង់។ សំនួរទីបីៈ តើការនោះអាចទៅរួចដោយរបៀបណា? ដើម្បីមិនត្រូវដាក់ក្រសែរភ្នែករបស់មើលពីអ្វីដែលអាចមើលឃើញ ប៉ុន្តែយើងត្រូវដាក់ក្រសែភ្នែក ក្រសែភ្នែកខាងព្រលឹងវិញ្ញាណរបស់យើងចំពោះអ្វីដែលមិនអាចមើលឃើញវិញ។

តើជីវិតនោះអាចកើតឡើងដោយរបៀបណា? វាអាចកើតឡើងបាន ពីព្រោះព្រះជាម្ចាស់បានប្រោសឲ្យយើងមានសេចក្ដីជំនឿ។ បងប្អូនឃើញទេ? ព្រះជាម្ចាស់មិនត្រាស់ហៅឲ្យបងប្អូនរាល់គ្នាមកអនុវត្តនូវអ្វីដែលទ្រង់មិនបានប្រទានមកបងប្អូននោះទេ។ សេចក្ដីជំនឿ ជាលទ្ធផលនៃកើតជាថ្មី ជាលទ្ធផលនៃកំណើតថ្មី ព្រះជាម្ចាស់បានប្រោសប្រទានឲ្យយើងមានជីវិតនិងពន្លឺ។ សាវក ប៉ុលបាននិយាយអំពីរឿងនោះនៅក្នុងផ្នែកនេះ។ ចូរយើងមើលជំពូក៤ *៦ ដ្បិតគឺជាព្រះ ដែលមានព្រះបន្ទូលបង្គាប់ ឲ្យមានពន្លឺភ្លឺចេញពីសេចក្ដីងងឹត ទ្រង់បានបំភ្លឺមកក្នុងចិត្តយើងខ្ញុំ ឲ្យយើងខ្ញុំមានរស្មីពន្លឺនៃដំណើរស្គាល់សិរីល្អរបស់ព្រះ ។* បងប្អូនឃើញទេ?ទ្រង់បានប្រទានដល់យើងនូវអ្វីម្យ៉ាងគឺ “ពន្លឺនៃការស្គាល់” ។ ទ្រង់បានឲ្យយើងនូវចំណេះដឹងជាក់លាក់មួយនៃសិរីល្អរបស់ទ្រង់គឺ “អំពីសិរីល្អនៃព្រះនៅក្នុងព្រះភក្រ័ព្រះយេស៊ូវគ្រីស្ទ”។ ទ្រង់បានប្រោសឲ្យយើងមានការមើលឃើញខាងព្រលឹងវិញ្ញាណ ដូច្នេះ នៅពេលនេះ អ្វីដែលព្រះជាម្ចាស់កំពុងតែត្រាស់ហៅយើងឲ្យធ្វើ គឺជាការអនុវត្តនូវអ្វីដែលយើងមាន។ ឥឡូវនេះយើងមានសមត្ថភាពក្នុងការជឿទ្រង់ មែនទេ? យើងដឹងថាព្រះបន្ទូលទ្រង់ជាការពិត។ ទ្រង់ប្រទានការមើលឃើញនេះ ដើម្បីឲ្យឃើញថា ព្រះជាម្ចាស់ពិតត្រង់ ស្មោះត្រង់ គួរទុកចិត្តបាន គួរថ្វាយបង្គំ ទោះបីជាមានអ្វីកើតឡើងនៅក្នុងជីវិតរបស់យើងក៏ដោយ។ ព្រះជាម្ចាស់បានប្រោសប្រទានឲ្យយើងមានតំរិះនោះ ហើយឥឡូវនេះទ្រង់កំពុងតែមានបន្ទូលមកយើងថា នេះជារបៀបដែលយើងត្រូវដើរ។ យើងត្រូវដើរដោយការមើលបែបយ៉ាងនោះ។ យើងត្រូវដើរជាមួយការយល់ដឹងដែលទ្រង់ប្រទានដល់យើងនោះ។ យើងបងប្អូនកំពុងតែប្រើរបៀបមើលដែលព្រះជាម្ចាស់បានប្រទានដល់បងប្អូនទេ? តើបងប្អូនកំពុងតែក្រលេកមើលការផ្សេងៗតាមរយៈព្រះនេត្រនៃព្រះជាម្ចាស់ដែរឬទេ ពីព្រោះឥឡូវនេះនៅក្នុងព្រះយេស៊ូវគ្រីស្ទ បងប្អូនអាច ហើយបងប្អូនដឹងថាបងប្អូនត្រូវតែធ្វើ។ តើបងប្អូនកំពុងតែធ្វើការនោះហើយឬ?

នេះនឹងនាំយើងទៅកាន់សំនួរទី៤គឺៈ ពេលណាយើងនឹងរស់នៅតាមរបៀបនេះ? គាត់និយាយថា “យើងដើរដោយសេចក្ដីជំនឿ មិនមែនដោយមើលឃើញទេ”។ តើការដែលត្រូវដើរដោយជំនឿ មិនមែនដោយការមើលឃើញ ជាការពិតនៅពេលណានៅជីវិតរបស់បងប្អូន? ខ្ញុំគិតថា នេះជាសំនួរដ៏សំខាន់មែនទែន។ យើងដែលជាអ្នកដែលបានរៀនពីអំណាចគ្រប់គ្រងទាំងអស់របស់ព្រះ ខ្ញុំគិតថាជួនកាលយើងប្រើភាសា "អំណាចគ្រប់គ្រងទាំងអស់" ដោយងាយៗ ប៉ុន្តែយើងមិនប្រើដោយទំនួលខុសត្រូវដោយងាយៗនោះទេ។ ខ្ញុំចង់និយាយទៅកាន់បងប្អូនប្រុសស្រីជាទីស្រឡាញ់នៅយប់នេះថា ការនេះនឹងបង្ហាញពីលក្ខណៈជាអ្នក

ជឿ ការនេះជាការប្រាកដច្បាស់មួយអំពីគំរូមួយក្នុងជីវិតរបស់អ្នកដែលបានទទួលសេចក្តីសង្គ្រោះ ពីព្រោះព្រះជាម្ចាស់បានប្រទានការមើលឃើញមក។ យើងមាននិស្ស័យថ្មីប្រាកដមែន។ យើងមានព្រះវិញ្ញាណបរិសុទ្ធដែលគង់នៅខាងក្នុងប្រាកដមែន ៤៥។ ការទាំងអស់នេះសុទ្ធតែជាការពិត។ ដូច្នេះនៅក្នុងគំនិតមួយនេះជាគំរូដែលធានាមួយនៅក្នុងជីវិតរបស់យើង។ ប៉ុន្តែ ចូរស្តាប់ យើងត្រូវតែជ្រើសរើសវា។ យើងត្រូវតែជ្រើសរើសក្នុងការដើរដោយសេចក្តីជំនឿ មិនមែនដោយការមើលឃើញទេ។ តែងតែមានជំរើសសំរាប់ឲ្យយើងជ្រើសរើសជារៀងរាល់ថ្ងៃ។ គ្រប់កាលៈទេសៈ គ្រប់ស្ថានភាព។ វានៅចំពោះមុខយើងម្តងទៀតហើយម្តងទៀតជារៀងរាល់ថ្ងៃ គ្រប់ពេល។ តើខ្ញុំនឹងជ្រើសរើសសេចក្តីជំនឿឬការមើលឃើញ? តើខ្ញុំនឹងជឿដល់ព្រះឬធ្វើការសម្រេចចិត្តតាមគំនិតរបស់លោកិយដែលកំពុងតែស្រែកការទូន្មានរបស់វាមកឯខ្ញុំនៅក្នុងកណ្តាលស្ថានភាពដែលខ្ញុំស្ថិតនៅ? និយាយឲ្យស្រួលស្តាប់ទៅ អ្វីដែលខ្ញុំចង់និយាយទៅកាន់បងប្អូនគឺយ៉ាងនេះ សូមស្តាប់ បងប្អូនមិនមែនកំពុងរស់នៅបែបនេះដោយគ្រាន់តែដឹងអំពីវានោះទេ ហើយក៏បងប្អូនមិនមែនរស់នៅដោយគ្រាន់តែសូត្រវាម្តងហើយម្តងទៀតនោះដែរ។ មិនមានឃ្លាមន្តអាគមគាថានៅក្នុងជីវិតគ្រីស្ទានទេ។ មិនមានការចាប់ជាតិឡើងវិញដែលគេអាចគ្រាន់តែនិយាយ។ គេនិយាយថាប្រសិនបើយើងគ្រាន់តែនិយាយវា វាក៏កើតឡើងបែបនោះ។ ទេ នេះគឺជាអ្វីម្យ៉ាងដែលបងប្អូនត្រូវជ្រើសរើស ហើយនេះក៏ជាជំរើសដ៏ពិបាកទៀតផង។ បងប្អូនត្រូវតែជ្រើសរើសដើរដោយសេចក្តីជំនឿ មិនដោយការមើលឃើញ។ ដូច្នេះមានព្រះបន្ទូលរបស់ព្រះនៅឯម្ខាង ហើយលោកិយនៅឯម្ខាងទៀត។ តើខ្ញុំនឹងជ្រើសរើសមួយណា? ខ្ញុំមានសេចក្តីបន្ទាល់របស់ភ្នែកខ្ញុំនៅឯម្ខាង ហើយខ្ញុំមានសេចក្តីបន្ទាល់នៃបទគម្ពីរនៅម្ខាងទៀត។ តើមួយណានឹងជាមូលដ្ឋានសំរាប់ឲ្យខ្ញុំធ្វើការសំរេចចិត្តបន្ទាប់មកទៀត? ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬក៏អ្វីដែលខ្ញុំអាចមើលឃើញ? យើងកំពុងរស់នៅបែបនេះនៅពេលយើងកំពុងរស់នៅបែបនេះ។ ប្រសិនបើសួរថានៅពេលណាយើងនឹងរស់នៅបែបនេះ? យើងកំពុងរស់នៅបែបនោះ នៅពេលយើងកំពុងរស់នៅបែបនោះ មិនមែននៅពេលយើងដឹងអំពីវានោះទេ ហើយក៏មិនមែននៅពេលយើងនិយាយអំពីវានោះដែរ ប៉ុន្តែនៅពេលយើងរស់នៅបែបនោះវិញ។

យើងត្រូវតែជ្រើសរើសការនេះជារៀងរាល់ថ្ងៃ ហើយគ្រប់ស្ថានភាព។ សំណួរចុងក្រោយរបស់ខ្ញុំគឺ តើការនោះនឹងមានលក្ខណៈយ៉ាងដូចម្តេច? តើការនោះនឹងមានលក្ខណៈយ៉ាងដូចម្តេច នៅពេលយើងកំពុងតែដើរដោយសេចក្តីជំនឿ មិនមែនដោយការមើលឃើញ? វាមានលក្ខណៈដូចជាផ្នែកនេះទាំងមូលនៅក្នុងភាពវិជ្ជមាន។ និយាយឲ្យស្រួលស្តាប់ទៅ វាមានលក្ខណៈ មិនណាយចិត្ត។ តើបងប្អូនធ្លាប់ធ្លាក់ទឹកចិត្តដែរឬទេ? តើបងប្អូនធ្លាប់អស់សង្ឃឹមដែរឬទេ? តើខ្ញុំជាមនុស្សតែម្នាក់ដែលនៅក្នុងបន្ទប់ ដែលមានបញ្ហាខកចិត្តដែលត្រូវដោះស្រាយ? ឬក៏ខ្ញុំមានអ្នកដទៃទៀតមានបញ្ហាដូចជាខ្ញុំដែរ? តើខ្ញុំមានអ្នកដទៃទៀតដែលដូចជាខ្ញុំទេ នៅយប់នេះ? ដូច្នេះនៅពេលដែលយើងជ្រើសរើសដើរដោយសេចក្តីជំនឿ មិនមែនដោយការមើលឃើញ យើងនឹងមិនអស់សង្ឃឹមទេ ពីព្រោះអ្វីដែលយើងមើលឃើញមិនមែនជាចុងបញ្ចប់ឡើយ មែនទេ? តើវាមានលក្ខណៈយ៉ាងដូម្តេច? វាមានលក្ខណៈដូចជា ការយល់ដឹងពីតួនាទីរបស់បងប្អូននៅក្នុងកិច្ចការសេចក្តីមេត្តាករុណារបស់ព្រះអង្គ។ បងប្អូនយល់ទេ? យើងទាំងអស់គ្នាជាអ្នកនាំសារនៃព្រះយេស៊ូវ

គ្រីស្ទនៅក្នុងលោកិយនេះ។ យើងទាំងអស់គ្នាជាបាវបំរើនៃការផ្សះផ្សារ ជាអ្នកប្រកាសដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយអ្វីទៀត ទាយមើល? យើងគ្រាន់តែជាភាជនៈដីប៉ុណ្ណោះ។ មានន័យថា នោះឯងជាតួនាទីរបស់យើង។ ប្រសិនបើបងប្អូនឆ្ងល់ ១១ "*យើងខ្ញុំមិនណាយចិត្តឡើយ*"។ ១១៦ "*យើងខ្ញុំមិនណាយចិត្តឡើយ*"។ ហេតុអី? ១៧ យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជនៈដី គាត់និយាយបន្តអំពីឥទ្ធិឫទ្ធិនៃព្រះកំពុងតែត្រូវបានដាក់តាំងបង្ហាញ? ហេតុអ្វីបានជាគាត់និយាយពីការទាំងនេះ? គាត់បាននិយាយបន្តទៀតនៅ១១១ "*ដ្បិតយើងរាល់គ្នាដែលរស់នៅ នោះយើងត្រូវប្រគល់ដល់សេចក្តីស្លាប់ជាដរាប ដោយព្រោះព្រះយេស៊ូវ ដើម្បីឲ្យព្រះជន្មនៃទ្រង់បានសំដែងមក ក្នុងរូបសាច់យើង ដែលតែងតែស្លាប់នេះ។ ហេតុនោះបានជាសេចក្តីស្លាប់កំពុងតែចំរើនឡើងក្នុងយើងខ្ញុំ តែជីវិតចំរើនក្នុងអ្នករាល់គ្នាវិញ*"។ ហេតុអ្វីបានលោកនិយាយរួមនឹងការនោះដែរ ប៉ុល? ពិតមែនហើយ ពីព្រោះគាត់និយាយថា "មើល អ្នកមិនណាយចិត្តឡើយនៅពេលណាអ្នកបានយល់ពីតួនាទីរបស់ខ្លួនជាអ្វី"។ យើងទាំងអស់គ្នាមានឯកសិទ្ធិដ៏អស្ចារ្យក្នុងការដែលយើងគ្រាន់តែធ្វើជាស្មបន្ទាល់នៃព្រះពិត ព្រះរាជបុត្រាពិតរបស់ទ្រង់ ហើយនិងសេចក្តីសង្គ្រោះពិត។ នោះឯងជាតួនាទីរបស់យើងនៅក្នុងពិភពលោកនេះ។ បងប្អូនឃើញទេ? អ្វីដែលជួនកាលធ្វើឲ្យយើងបាក់ទឹកចិត្តគឺថា យើងគិតពីខ្លួនឯងខ្ពស់ពេក ហើយយើងមាននិមិត្តដ៏ធំពេកក្នុងការដែលចង់ឲ្យខ្លួនក្លាយជាអ្វីហើយជោគជ័យអ្វីដែលយើងចង់ទទួល និងការជាច្រើនដែលស្រដៀងគ្នានេះ។ ខ្ញុំចង់និយាយថា ចិត្តរបស់យើងនឹងបានស្ងប់ ហើយចិត្តរបស់យើងនឹងបានសេចក្តីសុខសាន្ត ប្រសិនបើយើងអោបតួនាទីរបស់យើងឲ្យជាប់ ហើយនោះគឺ "ខ្ញុំជាភាជនៈដីឥដ្ឋដែលកើតមកដើម្បីថ្វាយសិរីល្អហើយប្រាប់គេអំពីទ្រង់និងព្រះរាជបុត្រារបស់ទ្រង់។ មូលហេតុនេះហើយបានជាខ្ញុំនៅទីនេះ។ ដូច្នេះហើយ ព្រះអម្ចាស់ហើយប្រសិនបើទ្រង់សព្វព្រះហឫទ័យបែបនោះនៅក្នុងជីវិតរបស់ទូលបង្គំតាមរយៈការរងទុក្ខលំបាករបស់ទូលបង្គំ ទូលបង្គំនៅតែអាចធ្វើបាន។ ប្រសិនបើទ្រង់សព្វព្រះហឫទ័យបែបនោះនៅក្នុងជីវិតរបស់ទូលបង្គំនៅពេលដែលងាយស្រួលជាង នោះក៏នៅតែជាគោលបំណងរបស់ទូលបង្គំ។ ទូលបង្គំកើតមកដើម្បីការនោះ។ ហេតុនេះហើយបានជាទូលបង្គំនៅទីនេះ"។

សូមមើលទៅជំពូក៥ ១៩ បន្ទាប់មកនៅ១៨ "*ដូច្នេះ យើងខ្ញុំមានចិត្តជឿជាក់ ហើយក៏សុខចិត្តស៊ូចេញពីរូបកាយនេះ ទៅនៅជាមួយនឹងព្រះអម្ចាស់ជាជាង។ ហេតុនោះបានជាយើងខ្ញុំសង្វាត ឲ្យបានគាប់ដល់ព្រះហឫទ័យទ្រង់ ទោះនៅក្នុងរូបកាយ ឬឃ្លាតពីរូបកាយក្តី*"។ ខ្ញុំចង់មានន័យថា បើសិនបើខ្ញុំនៅលើផែនដីនេះ ឬថ្ងៃមួយខ្ញុំកំពុងឈរនៅចំពោះព្រះយេស៊ូវ តើអ្វីជាគោលបំណងរបស់ខ្ញុំ? ខ្ញុំគ្រាន់តែចង់ដឹងថា ខ្ញុំបានគាប់ដល់ព្រះហឫទ័យទ្រង់។ ដូច្នេះខ្ញុំគ្រាន់តែជាភាជនៈដីឥដ្ឋ
ប៉ុណ្ណោះ។ ខ្ញុំជាមនុស្សទន់ខ្សោយម្នាក់ដែលបានទទួលសេចក្តីសង្គ្រោះដោយសារព្រះគុណនៃព្រះ ខ្ញុំជាកម្មបទមួយនៃសេចក្តីមេត្តាករុណារបស់ព្រះ ហើយខ្ញុំកើតមកដើម្បីហេតុផលមួយប៉ុណ្ណោះគឺដើម្បីផ្គាប់ដល់ព្រះហឫទ័យទ្រង់។ ខ្ញុំអាចធ្វើការនោះបានទោះជាមានស្ថានភាពអ្វីក៏ដោយ ប្រសិនបើខ្ញុំដើរដោយជំនឿមិនមែនដោយការមើលឃើញ។ វាមើលទៅដូចជាសេចក្តីស្មោះត្រង់ចំពោះព្រះរាជសារដំណឹងល្អ សេចក្តីស្មោះត្រង់ចំពោះមធ្យោបាយដំណឹងល្អ។ នោះជាអ្វីដែលបានចែងនៅក្នុង១២និង១៣។ យើងនឹងមិនបំផ្លែង

ព្រះបន្ទូលរបស់ព្រះទេ។ យើងនឹងមិនពាក់ព័ន្ធនឹងល្បិចកលណាឡើយ។ យើងដឹងថាព្រះជាម្ចាស់សង្គ្រោះមនុស្សមានបាប។ ទ្រង់សង្គ្រោះមនុស្សមានបាប គ្មានការសំរុះសំរួលឡើយ។ នោះមានលក្ខណៈជាសេចក្ដីជំនឿ មិនមែនជាការមើលឃើញទេ។ តើបងប្អូនដឹងទេនៅដែលមនុស្សម្នាក់ដូចជាប៉ុល បច្ចុប្បន្ននេះ នៅពេលបងប្អូនកំពុងធ្វើព័ន្ធកិច្ច ប្រហែលជាព័ន្ធកិច្ចទៅកាន់គ្រួសាររបស់បងប្អូន នៅពេលដែលព្រះបន្ទូលរបស់ព្រះហើយនិងវិធីសាស្ត្ររបស់ព្រះហាក់ដូចជាមិនបានទទួលលទ្ធផលអ្វី តើបងប្អូននឹងជឿអ្វី? ព្រះបន្ទូលរបស់ព្រះឬក៏ភ្នែករបស់បងប្អូន? បងប្អូននឹងអាចស្មោះត្រង់ចំពោះដំណឹងល្អបានទេ ប្រសិនបើបងប្អូនមិនជឿដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ វានឹងមើលទៅដូចជាសេចក្ដីសង្ឃឹម។ ជាជីវិតដែលបានរស់នៅក្នុងពន្លឺនៃថ្ងៃអនាគតមួយ។ យើងរាល់គ្នាកំពុងតែរស់នៅក្នុងពន្លឺនៃភាពអស់កល្ប។ វានឹងមើលទៅដូចជាសេចក្ដីក្លាហានដែលមិនអាចពន្យល់បានដោយស្ថានភាព។ តើពេលណាជាពេលចុងក្រោយដែលបងប្អូនបង្ហាញសេចក្ដីក្លាហានបរិសុទ្ធមួយដែលមិនអាចពន្យល់ដោយស្ថានភាពរបស់បងប្អូនបាន? ខ្ញុំចង់មានន័យថា មនុស្សគ្រប់គ្នាជុំវិញបងប្អូននិយាយថា “ខ្ញុំមិនដឹង។ ខ្ញុំមិនដឹងពីរបៀបដែលអ្នកមានសេចក្ដីសុខសប្បាយយ៉ាងនេះទេ”។ ហើយមូលហេតុដែលបងប្អូនអាចនិយាយពីរបៀបដែលបងប្អូនបានសុខសប្បាយគឺពីព្រោះបងប្អូនកំពុងតែដើរដោយសេចក្ដីជំនឿ មិនមែនដោយការមើលឃើញទេ។ “ខ្ញុំជឿលើគំនិតរបស់ព្រះជាម្ចាស់ចំពោះស្ថានភាពនេះ”។ វានឹងមើលទៅដូចជាសេចក្ដីអត់ធ្មត់។ វាមើលទៅដូចជាការតស៊ូខ្ជាប់ខ្ជួន។ មែនទេ? យើងមិនណាយចិត្តទេ។ យើងតែងមានសេចក្ដីក្លាហានជានិច្ច។ យើងតែងមានសេចក្ដីក្លាហានជានិច្ច នោះមានន័យថា នោះជាការអត់ធ្មត់ នោះជាការតស៊ូខ្ជាប់ខ្ជួនពីព្រោះយើងជឿដល់ព្រះជាម្ចាស់។ ខ្ញុំនឹងប្រាប់ដល់បងប្អូននូវការមួយផ្សេងទៀត ហើយខ្ញុំសង្ឃឹមថាការនេះនឹងលើកទឹកចិត្តដល់បងប្អូន។ វានឹងដូចជាម្នាក់ដែលអាចស្មោះត្រង់និងពិតត្រង់អំពីការឈឺចាប់របស់ពួកគេ ប៉ុន្តែនៅពេលដំណាលគ្នានោះ ដោយសេចក្ដីស្មោះត្រង់ និងភាពស្មោះត្រង់ ពួកគេអរព្រះគុណដល់ព្រះហើយរាប់ការនោះថាជាព្រះពរវិញ។ នោះជាអ្វីដែលបងប្អូនឃើញនៅក្នុងជំពូក៤ ចាប់ផ្ដើមពីខ៨។ សូមមើលពីខ៧មក *យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជនៈដី ដើម្បីឲ្យឥទ្ធិឫទ្ធិលើសលប់បានមកពីព្រះ មិនមែនពីយើងខ្ញុំទេ ដែលយើងខ្ញុំត្រូវគេសង្កត់សង្កិនគ្រប់ជំពូក*”។ នោះជាការពិតមែនទេ? យើងត្រូវបានគេសង្កត់សង្កិន។ ប៉ុន្តែតើបងប្អូនដឹងទេ? យើង” *មិនទ័លផ្លូវឡើយ មានសេចក្ដីវិលវល់ តែមិនទ័លគំនិតទេ*”។ តើនៅពេលណាជាពេលចុងក្រោយ ដែលបងប្អូនរាល់គ្នាសារភាពថា បងប្អូន*មានសេចក្ដីវិលវល់ តែមិនទ័លគំនិត?* “ខ្ញុំមិនយល់ពីរឿងនេះ។ នេះជាដំណើរការដ៏ពិបាកសំរាប់ខ្ញុំណាស់”។ នៅទីនេះសាវក ប៉ុលនិយាយថា “ជួនកាលខ្ញុំមានសេចក្ដីវិលវល់។ ប៉ុន្តែការនេះមិនធ្វើឲ្យមានការអស់សង្ឃឹមនោះទេ។ ហេតុអ្វី? ពីព្រោះព្រះបន្ទូលរបស់ព្រះពិតត្រង់។ “ត្រូវបានបៀតបៀន” នេះជាការពិត។ បច្ចុប្បន្ននេះ យើងមានបងប្អូនប្រុសស្រីរបស់យើងនៅប្រទេសអ៊ីរ៉ាក់និងកន្លែងដទៃទៀតដែលទើបតែទទួលការបៀតបៀនយ៉ាងខ្លាំង។ ប៉ុន្តែបងប្អូនដឹងទេ? ព្រះជាម្ចាស់”មិនដែលបោះបង់ចោលពួកគេឡើយ”។ ពួកគេមិនដែលត្រូវទទួលបានការបោះបង់ហើយពួកគេនឹងមិនរស់នៅដោយមើលពីស្ថានភាពនានាដែលកើតឡើង។ ពួកគេមិនរស់នៅដោយសំឡឹងមើលស្ថានភាពទេ។ ពួកគេត្រូវសំឡឹងមើលទៅឯព្រះបន្ទូលរបស់ព្រះ។

“បំផ្លាញ”។ តើបងប្អូនធ្លាប់ត្រូវបានគេសង្កត់សង្កិនទេ? តើថ្មីៗនេះ បងប្អូនត្រូវបានគេសង្កត់សង្កិនឬទេ? សូមស្ដាប់។ “មិនមែនត្រូវបានបំផ្លាញទេ តែងតែនៅជាប់នឹងរូបកាយ ការសុគតនៃព្រះគ្រីស្ទ ដើម្បីឲ្យជីវិតនៃព្រះគ្រីស្ទត្រូវបានបង្ហាញនៅក្នុងជីវិតរបស់យើង នៅក្នុងរូបកាយរបស់យើងវិញ។ ដ្បិតយើងតែងតែងរស់នៅលើសសេចក្ដីស្លាប់ដោយយល់ដល់ព្រះយេស៊ូវ ដើម្បីឲ្យជីវិតនៃព្រះយេស៊ូវនោះអាចបង្ហាញឲ្យឃើញនៅក្នុងសាច់ឈាមដែលចេះស្លាប់របស់យើង”។ ព្រះជាម្ចាស់បានដាក់យើងនៅក្នុងស្ថានភាពនានាដើម្បីបង្ហាញពីអង្គទ្រង់។ ព្រះជាម្ចាស់បានដាក់យើងនៅក្នុងស្ថានភាពនានាដើម្បីបង្ហាញពីអង្គទ្រង់។ សេចក្ដីស្លាប់របស់យើងមានន័យថា ការបង្ហាញនៃជីវិតរបស់ទ្រង់។ នោះឯងជាហេតុផលដែលត្រូវរស់នៅ។ នោះឯងជាហេតុផលដែលត្រូវមានសេចក្ដីអំណរ។ ទោះបីជាបងប្អូនឆ្លងកាត់អ្វីយ៉ាងណាក៏ដោយ។ ដូច្នេះនៅក្នុងកណ្ដាលផ្នែកដ៏មានតំលៃអស្ចារ្យនេះ បងប្អូនមានគំនិតមួយដែលនៅចន្លោះនោះ។ មិនមានប្រយោគឥតប្រយោជន៍ណានៅក្នុងបទគម្ពីរឡើយ “ដ្បិតយើងដើរដោយសេចក្ដីជំនឿ មិនមែនដោយការមើលឃើញឡើយ”។

សូមអធិស្ឋាន។

*ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំយើងខ្ញុំសូមអរព្រះគុណទ្រង់ដែលទ្រង់បានប្រទានឲ្យកូនទាំងអស់គ្នាមានសេចក្ដីជំនឿនៅក្នុងព្រះរាជបុត្រារបស់ទ្រង់។ ទ្រង់បានប្រទានមកឯទូលបង្គំយើងខ្ញុំដោយកិច្ចការនៅក្នុងវិញ្ញាណរបស់ទ្រង់ គឺជាភ្នែកដើម្បីឲ្យបានឃើញ។ ភ្នែកដែលអាចមើលឃើញការពិតនៃសេចក្ដីលោកិយនេះនៅក្នុងពន្លឺរបស់វា ហើយនិងភ្នែកដើម្បីឲ្យបានឃើញពីអនាគតដ៏អស់កល្បដែលទូលបង្គំយើងខ្ញុំមិនទាន់មើលឃើញនៅឡើយ ប៉ុន្តែអាចឃើញការទាំងអស់នោះដោយសេចក្ដីជំនឿវិញ ហើយនិងដើម្បីរស់នៅក្នុងពន្លឺនៃសេចក្ដីទាំងនោះរហូតទាល់តែទូលបង្គំយើងខ្ញុំជួបសេចក្ដីទាំងនោះមុខទល់នឹងមុខវិញ។ ដូច្នេះទូលបង្គំសូមអធិស្ឋានសំរាប់ទូលបង្គំនិងបងប្អូនប្រុសស្រីនៅវេលាយប់នេះ ទូលបង្គំអធិស្ឋានសូមឲ្យទូលបង្គំយើងខ្ញុំជ្រើសរើសជីវិតនេះដែលបង្ហាញពីលក្ខណ:របស់ទូលបង្គំយើងខ្ញុំនៅទីបញ្ចប់វិញ ហើយថាយើងខ្ញុំនឹងជ្រើសរើសជីវិតនេះដោយការដើរ ការដើរដោយសេចក្ដីជំនឿ មិនមែនដោយការមើលឃើញទេ។ សូមទ្រង់ចំរើនកំលាំងបងប្អូនរបស់ទូលបង្គំដើម្បីឲ្យបានជឿដល់ព្រះបន្ទូលរបស់ទ្រង់ហើយនិងកន្លែងណាដែលត្រូវធ្វើការសំរេចចិត្ត កន្លែងណាដែលមានការដែលត្រូវធ្វើ កន្លែងណាដែលមានឥរិយាបថដែលត្រូវសំដែង ឱព្រះអម្ចាស់អើយ សូមចំរើនកំលាំងដល់រាស្ត្ររបស់ទ្រង់ដើម្បីឲ្យបានដឹងថា ព្រះបន្ទូលរបស់ទ្រង់គឺពិតត្រង់ ដើម្បីធ្វើការសំរេចចិត្ត ដើម្បីនិយាយ ដើម្បីបង្ហាញឥរិយាបថនៅក្នុងពន្លឺនៃអ្វីទ្រង់មានបន្ទូល មិនមែនដោយមើលឃើញឡើយ។  ព្រះអម្ចាស់អើយ ទូលបង្គំយើងខ្ញុំមិនអាចធ្វើការនេះបានទេ បើគ្មានទ្រង់។ ទូលបង្គំសំឡឹងទៅឯទ្រង់ហើយសូមទ្រង់សំរាប់ការទាំងអស់នេះនៅក្នុងព្រះនាមនៃព្រះដែលបានសង្គ្រោះទូលបង្គំយើងខ្ញុំ នៅក្នុងព្រះនាមនៃព្រះអង្គសង្គ្រោះ ស្ដេច និងអ្នកគង្វាលរបស់ទូលបង្គំយើងខ្ញុំ គឺនៅក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន។*